# ព្រឹត្តិបត្រប្រចាំត្រីមាសទី៣

*ទឹកស្អាតសម្រាប់មនុស្សគ្រប់រូប*

ខែកក្កដា ដល់ ខែកញ្ញា ឆ្នាំ២០២៣

## ១. បច្ចុប្បន្នភាពសមាគម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃជាឯកជនមិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះមិនផ្តល់ជាសម្ភារ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។ សមាគមបម្រើឱ្យផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈតាមលទ្ធភាពដែលសមាគមអាចចូលរួមបាន។

សមាគមបង្កើតឡើងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ដោយក្រុមអ្នកផ្គត់ផ្គង់ទឹកស្អាតឯកជនមួយក្រុមមានគ្នាប្រមាណជា ២០នាក់ ក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ របស់គម្រោង អេម អេស អេម អ៊ី កម្ពុជា (MSME) ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) និងបានចុះបញ្ជីសមាគមជាផ្លូវការនៅក្រសួងមហាផ្ទៃ តាមសេចក្តីជូនដំណឹងលេខៈ ១០៧៧ សជណ របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១២។ ក្រសួងមហាផ្ទៃចេញសេចក្តីប្រកាសលេខ: ២៩០១ប្រក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ សម្រេចចុះឈ្មោះសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ឡើងវិញក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គល នៅក្រសួងមហាផ្ទៃ ដោយមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលស្ថិតនៅអគារF ជាន់ទី២ បន្ទប់លេខ២៦៩ នៃមជ្ឈមណ្ឌលភ្នំពេញ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

សមាគមបង្កើតឡើងក្នុងគោលបំណងប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់និន្នាការនយោបាយអ្វីឡើយ។

> គិតត្រឹមបំណាច់ត្រីមាសទី៣ ឆ្នាំ២០២៣ សមាគមមានសមាជិកសរុបចំនួន ៣៣៦ស្ថានីយ/ក្រុមហ៊ុន ដែលក្នុងនោះមានសមាជិកអាជីពចំនួន ២៩៣ បាននឹងកំពុងប្រតិបត្តិការនៅក្នុង ២៣រាជធានី/ខេត្ត/ក្រុង នៃព្រះរាជាណាចក្រកម្ពុជា និងសមាជិកគាំទ្រចំនួន ៤៣ក្រុមហ៊ុន/ស្ថានីយ។

# ២.  ការងារស្នូលសមាគម

## ២.១. ក្រុមប្រឹក្សាភិបាល

### ២.១.១. កិច្ចប្រជុំវិសាមញ្ញ

នៅក្នុងត្រីមាសទី៣ សមាគមបានរៀបចំកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាភិបាលចំនួន ៣លើក៖

១. **លើកទី១៖** នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៣ ពិភាក្សាលើរបៀបវារៈចំនួនពីរគឺ ១. ដំណើរទស្សនកិច្ចទៅកាន់រោងចក្រផលិតទុយោរបស់ក្រុមហ៊ុន LESSO PIPES (CAMBODIA) TRADING CO., Ltd នៅមានទីតាំងស្ថិតនៅភូមិព្រៃការ ឃុំធក់ឈើនាង ស្រុកអង្គស្នួល ខេត្តកណ្ដាល និង ២. ពិភាក្សាអំពីបញ្ហាគុណភាពទឹករបស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតបត់រកា ស្ថិតនៅស្រុកសំរោង ខេត្តតាកែវ ដែលមានការចុះផ្សាយលើបណ្ដាញសង្គម CTV Online។ ជាលទ្ធផលអង្គប្រជុំបានសម្រេចដូចខាងក្រោម៖

- ក្រុមប្រឹក្សាភិបាល និងបុគ្គលិកសមាគមទាំងអស់នឹងរៀបចំទស្សនកិច្ចសិក្សានៅក្រុមហ៊ុន LESSO PIPES (CAMBODIA) TRADING CO., Ltd នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង០៩:០០ព្រឹក។
- ចំពោះករណីបញ្ហាគុណភាពទឹកនៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតបត់រកា សមាគមនឹងចាត់តាំងមន្ត្រីទំនាក់ទំនង និងមន្ត្រីបច្ចេកទេស ដើម្បីចុះទៅសិក្សាស្រាវជ្រាវ និងអញ្ជើញ **លោក ហែម ម៉ាច** ដែលជាម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតបត់រកា ដើម្បីមកប្រជុំជាមួយក្រុមប្រឹក្សាភិបាល នៅការិយាល័យរបស់សមាគម។

២. **លើកទី២៖** នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២ ប្រជុំជាមួយ **លោក ហែម ម៉ាច** ម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតបត់រកា ដើម្បីសិក្សាពីមូលហេតុដែលបណ្ដាលឲ្យមានបញ្ហាប៉ះពាល់ដល់គុណភាពប្រភពទឹកនៅក្នុងបឹងបត់រកា ព្រមទាំងវិភាគពីលទ្ធផលនៃគុណភាពទឹកស្អាតនៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតបត់រកា (ការប្រើប្រាស់សារធាតុគីមីដើម្បីសម្អាតទឹក ការវិភាគទៅលើគុណភាពទឹកឆៅ និងការវិភាគទៅលើគុណភាពទឹកស្អាត)។ កិច្ចប្រជុំនេះក៏បានផ្ដល់អនុសាសន៍ និងលើកផែនការដែលនឹងត្រូវអនុវត្តបន្តសម្រាប់រយៈពេលមធ្យម (៦ខែ ទៅ១ឆ្នាំ) និងរយៈពេលវែង (១ឆ្នាំ ទៅ៣ឆ្នាំ)។



*រូបភាពទី១៖ កិច្ចប្រជុំពិភាក្សាករណីគុណភាពទឹករបស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតបត់រកានៅការិយាល័យសមាគម*

៣. **លើកទី៣៖** ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ ពិភាក្សាលើរបៀបវារៈចំនួន៣ គឺ ១. ការរៀបចំកិច្ចប្រជុំថ្នាក់តំបន់ ២.ការជ្រើសរើសសវនកម្មខាងក្រៅ និង ៣.ការសម្រេច និងដោះស្រាយបញ្ហាសមាជិកដែលមិនទាន់បានបង់ប្រាក់ភាគទានសមាជិកតាំងពីឆ្នាំ២០២១។ ជាលទ្ធផលអង្គប្រជុំបានសម្រេចដូចខាងក្រោម៖

- ❖ កិច្ចប្រជុំថ្នាក់តំបន់នឹងរៀបចំនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ នៅសណ្ឋាគារភ្នំប្រុស ខេត្តកំពង់ចាម ដោយអញ្ជើញប្រតិបត្តិករមកពី ៥ខេត្តរួមមាន៖ ខេត្តកំពង់ធំ កំពង់ចាម ត្បូងឃ្មុំ ក្រចេះ និងខេត្តព្រៃវែង ហើយកិច្ចប្រជុំថ្នាក់តំបន់នេះទទួលបានការឧបត្ថម្ភពីក្រុមហ៊ុន LESSO។
- ❖ បន្ទាប់ពីធ្វើការពិនិត្យ និងពិចារណាយ៉ាងលម្អិតទៅលើក្រុមហ៊ុនសវនកម្មទាំង៤ អង្គប្រជុំបានឯកភាពសម្រេចជ្រើសរើសយកក្រុមហ៊ុន V Chartered Accountants Co., Ltd សម្រាប់រយៈពេល២ឆ្នាំ (២០២១ និង២០២២)។
- ❖ ក្នុងត្រីមាសទី៣នេះ ស្ថានីយទឹកស្អាតចំនួន៧ ក្នុងចំណោមស្ថានីយទាំង១៣ ដែលមិនទាន់បានបង់ប្រាក់សមាជិកភាពចាប់តាំងពីឆ្នាំ២០២១ បានបង់ប្រាក់សមាជិកភាពមកសមាគម។

## ២.១.២.ការជួបសម្តែងការគួរសម និងអបអរសាទរ ឯកឧត្តម ហែម វណ្ណឌី រដ្ឋមន្ត្រីក្រសួងឧវបន

ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ដឹកនាំដោយ **លោក ឡេង ឌៀវ** ប្រធានក្រុមប្រឹក្សាភិបាល បានចូលជួបសម្តែងការគួរសម និងអបអរសាទរ ជូនចំពោះ **ឯកឧត្តម ហែម វណ្ណឌី** ក្នុងឱកាសដ៏ថ្លៃថ្លា ដែលរដ្ឋសភាបានបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត និងគាំទ្រជា រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍(ឧវបន) នីតិកាលទី៧ កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ កន្លងទៅថ្មីៗនេះ។ ក្នុងជំនួបនេះដែរ **ឯកឧត្តមរដ្ឋមន្ត្រី** បានផ្តល់ជាអនុសាសន៍ណែនាំដ៏ថ្លៃថ្លា ដើម្បីជាចក្ខុវិស័យសម្រាប់សមាគមក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ និងអនុវត្តការងាររបស់ខ្លួនឱ្យបានកាន់តែល្អប្រសើរ។



*រូបភាពទី២៖ ការចូលជួបសម្តែងការគួរសម និងអបអរសាទរចំពោះ **ឯកឧត្តម ហែម វណ្ណឌី** រដ្ឋមន្ត្រីក្រសួង ឧវបន*

## ២.២. ការចូលជាសមាជិកថ្មីរបស់សមាគម

ក្នុងត្រីមាសទី៣ សមាគមទទួលបានសមាជិកថ្មីចំនួន ៧ស្ថានីយ/ក្រុមហ៊ុន រួមមាន៖

| ល.រ | ឈ្មោះស្ថានីយ ឬក្រុមហ៊ុន | អាសយដ្ឋាន |
|---|---|---|
| **សមាជិកអាជីពចំនួន ៤ស្ថានីយ៖** | | |
| ១ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឆាង សោភា | ភូមិបាសាក់ ឃុំបាសាក់ ស្រុករុក្ខគីរី ខេត្តបាត់ដំបង |
| ២ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ភូមិយើង | ភូមិថ្មពេជ្រទី២ ឃុំថ្មពេជ្រ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ |
| ៣ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ស្រស់សេរីសោភ័ណ ញ៉ៅទី២ | នៅភូមិតាង៉កទន្លេ ឃុំញ៉ៅទី២ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង |
| ៤ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត លកភ្នំមាស | ភូមិលក ឃុំឫស្សីស្រុកខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត (គាត់បានចុះឈ្មោះចូលជាសមាជិកឡើងវិញ) |
| **សមាជិកគាំទ្រចំនួន ៣ក្រុមហ៊ុនរួមមាន៖** | | |
| ៥ | ក្រុមហ៊ុន អាល់ហ្វា វ៉ាធើរ & អេឡិកទ្រីក សឺបផ្លាយ ឯ.ក | #R2 ផ្លូវ២៦៥Z ក្រុមទី៤៤ ភូមិ១៣ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ |
| ៦ | ក្រុមហ៊ុន គីមស៊ូ អ៊ិនធើណេសិនណល ឯ.ក | ផ្លូវលំ ភូមិព្រៃជីសាក់ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ |
| ៧ | ក្រុមហ៊ុន ឌីណាមិុច អេនើជី សឹលូសិន ឯ.ក | #៤៥៨A ភូមិក្រពើហា សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល |

## ២.៣. ការដោះស្រាយបញ្ហារបស់សមាជិក

ក្នុងត្រីមាសទី៣ សមាគមបានសហការជាមួយមន្ទីរ ឧរបន ខេត្តតាកែវ និងខេត្តកំពង់ស្ពឺ ដើម្បីដោះស្រាយបញ្ហាគុណភាពទឹក និងប្រភពទឹកបានចំនួន ២ករណី៖

១. **ករណីទី១៖** ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣ បុគ្គលិកសមាគម លោកប្រធានមន្ទីរ និងលោកអនុប្រធានមន្ទីរ ឧរបន ខេត្តតាកែវ បានចុះទៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតបត់រការ ដើម្បីសួរសុខទុក្ខ និងសួរនាំពីបញ្ហាគុណភាពប្រភពទឹករបស់**លោក ហែម ម៉ាច** ដែលមានការចុះផ្សព្វផ្សាយលើបណ្ដាញសង្គមរបស់ CTV online។



*រូបភាពទី៣៖ ប្រភពទឹកផៅនៅបឹងបត់រកា*

ក្រោយពីពិនិត្យមើលស្ថានភាពទឹកជាក់ស្តែង នៅក្នុងបឹងបត់រការរួចមក លោកប្រធានមន្ទីរ លោកអនុប្រធានមន្ទីរ ឧរបន ខេត្តតាកែវ និងបុគ្គលិកសមាគមបានផ្តល់ជាអនុសាសន៍ និងផែនការដែលត្រូវធ្វើបន្តរួមមាន៖

❖ **<u>ផែនការដែលត្រូវធ្វើបន្ទាន់ (បច្ចុប្បន្ន)</u>**

ក. ត្រូវដាក់សាច់ជូរជុំលាយជាមួយធ្យូង ខ្សាច់ និងថ្ម 1x2 ដាក់ក្នុងសំណាញ់ជុំវិញមាត់ស្រះដែលបានស្តារថ្មីៗនោះ ដើម្បីសម្អាតដំបូង និងកាត់បន្ថយក្លិនពីប្រភពទឹកមុននឹងបូមឡើងមកកាន់អាងប្រព្រឹត្តិកម្ម។

ខ. ត្រូវការពាកុំឱ្យសំរាម កញ្ជែត ត្រគៀតមកក្បែរស្ថានីយបូមទឹកឆៅ ដោយត្រូវដាក់សំណាញ់ព័ទ្ធជុំវិញដើម្បីការពារ ។

គ. ត្រូវរៀបចំប្រព័ន្ធខ្សែភ្លើងនៅកន្លែងស្ថានីយបូមទឹកឆៅឱ្យមានរបៀបរៀបរយ និងទៅតាមបច្ចេកទេសក្នុងការការពារគ្រោះថ្នាក់ផ្សេងៗដែលអាចកើតមានឡើង។

❖ **<u>ផែនការសម្រាប់រយៈពេលយូរ (១ឆ្នាំ ទៅ៣ឆ្នាំ)</u>**

ក. ម្ចាស់ស្ថានីយត្រូវស្នើសុំស្តារបឹងបត់រកាឡើងវិញ ដើម្បីយកទឹកមកប្រើប្រាស់ និងជៀសវាងការកើតមានបញ្ហានៅឆ្នាំបន្ទាប់ទៀត។

ខ. បន្ទាប់ពីស្តារបឹងបត់ការួច ត្រូវដាក់សំណាញ់ព័ទ្ធជុំវិញកន្លែងដែលបានស្តារ កុំឱ្យកញ្ជែត ត្រីបកំប្លោក និងត្រគៀតចូលមកក្នុងតំបន់ដែលស្តាររួច។

គ. ត្រូវជូនដំណឹងដល់អាជ្ញាធរពាក់ព័ន្ធអំពីបញ្ហាគុណភាពទឹកស្អាតដែលអាចកើតមានឡើងនៅក្នុងរដូវវស្សា និងការខ្វះខាតទឹកប្រើប្រាស់នៅក្នុងរដូវប្រាំង ដើម្បីរំលឹកទៅដល់អ្នកពាក់ព័ន្ធនានា។

២. **ករណីទី២៖** ថ្ងៃទី១២ និង ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ បុគ្គលិកសមាគមសហការជាមួយមន្ទីរ ឧរបន ខេត្តកំពង់ស្ពឺ បានជួបប្រជុំជាមួយអាជ្ញាធរឃុំព្រៃវិហារ មេភូមិ និងអ្នកតំណាងភូមិដំរីស្លាប់ ព្រមទាំងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតព្រៃកែស ដើម្បីដោះស្រាយបញ្ហាប្រភពទឹកដែលកើតមានឡើងនៅក្នុងតំបន់របស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតព្រៃកែស។ លទ្ធផលនៅក្នុងកិច្ចប្រជុំទាំងពីរលើកនេះរួមមាន៖

❖ ប្រជាពលរដ្ឋនៅក្នុងភូមិដំរីស្លាប់នៅតែប្រកាន់ជំហរដាច់ខាតគឺមិនឱ្យស្ថានីយផ្គត់ផ្គង់ទឹកស្អាតព្រៃកែសបន្តបូមទឹកបឹងកញ្ជោតនេះតទៅទៀតបានឡើយ។

❖ ជាជំហានបន្ទាប់ប្រជាពលរដ្ឋនៅក្នុងភូមិដំរីស្លាប់ និងស្ថានីយផ្គត់ផ្គង់ទឹកស្អាតព្រៃកែសនឹងបន្តការដោះស្រាយបញ្ហានេះ នៅថ្នាក់ខេត្តជាបន្តទៀត។



*រូបភាពទី៤៖ លោកមេឃុំស្តីទីនៃឃុំព្រៃវិហារពន្យល់ប្រជាពលរដ្ឋពីផលប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាត*

## ២.៤. កិច្ចសហការអន្តរជាតិ

### ❖ ទស្សនកិច្ចសិក្សានៅក្រៅប្រទេស

តបតាមការអញ្ជើញរបស់សមាគមទឹកម៉ាឡេស៊ី សមាគមបានដឹកនាំគណៈប្រតិភូកម្ពុជាដែលជាសមាជិករបស់ខ្លួនចំនួន ៣១នាក់ (ស្រី ១២នាក់) ដើម្បីចូលរួមក្នុងវេទិកាទឹកលើកទី៥ និងសន្និសីទថ្នាក់តំបន់ ស្តីពីការគ្រប់គ្រងទឹកស្អាត និងទឹកកខ្វក់ ក្រោមប្រធានបទ«ការពង្រឹងនៃការគ្រប់គ្រងទឹក និងបរិស្ថាននៅអាស៊ីប៉ាស៊ីហ្វិក តាមរយៈបច្ចេកវិទ្យាបៃតង និងភាពជាដៃគូ» ចាប់ពីថ្ងៃពុធ ទី៣០ ខែសីហា ដល់ថ្ងៃសុក្រ ទី០១ ខែកញ្ញា ឆ្នាំ២០២៣ នៅជាន់ទី១ បន្ទប់សន្និសីទ MR110ABC នៅមជ្ឈមណ្ឌលសន្និបាតជាតិ Queen Sirikit National Convention Center (QSNCC) ទីក្រុងបាងកក ព្រះរាជាណាចក្រថៃ។ នៅក្នុងដំណើរទស្សនកិច្ចនេះ គណៈប្រតិភូកម្ពុជាទទួលបានលទ្ធផលដូចខាងក្រោម៖

- ❖ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣ ទស្សនាអាងប្រព្រឹត្តិកម្មផលិតទឹកស្អាត Bangken របស់អាជ្ញាធររដ្ឋាករទឹកទីប្រជុំជន MWA (Metropolitan Waterworks Authority) ដើម្បីស្វែងយល់អំពី៖ ១). ទិដ្ឋភាពទូទៅនៃ MWA ២). ប្រភពទឹកឆៅ និងប្រព័ន្ធបញ្ជូនទឹកឆៅ ៣). ដំណើរការសម្អាតទឹក ៤). ប្រព័ន្ធចែកចាយទឹកស្អាត ៥). ការគ្រប់គ្រងគុណភាពទឹក ៦). ការផ្សព្វផ្សាយពីគុណភាពទឹកស្អាតជូនសាធារណៈជនតាមអនឡាញ។




*រូបភាពទី៥៖ ទស្សនាអាងប្រព្រឹត្តិកម្មផលិតទឹកស្អាត*

- ❖ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ គណៈប្រតិភូកម្ពុជាបានចូលរួម៖
  - ក. កម្មវិធីបើកជាផ្លូវការ ស្តីពីវេទិកាទឹកលើកទី៥ ក្រោមប្រធានបទ«**ការពង្រឹងនៃការគ្រប់គ្រងទឹក និងបរិស្ថាននៅអាស៊ីប៉ាស៊ីហ្វិក តាមរយៈបច្ចេកវិទ្យាបៃតង និងភាពជាដៃគូ**»
  - ខ .ទស្សនាពិព័រណ៍ទឹក Thai Water Expo 2023 ដែលដឹកនាំដោយក្រុមការងារ Informa Markets
  - គ .ពិសារអាហារសាមគ្គី និងកសាងទំនាក់ទំនងធុរៈកិច្ច។




*រូបភាពទី៦៖ ពិធីបើកកម្មវិធីជាផ្លូវការ ស្តីពីវេទិកាទឹកលើកទី៥*



*រូបភាពទី៧៖ ពិសាអាហារសាមគ្គី និងកសាងទំនាក់ទំនងធុរៈកិច្ច*

❖ **ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣៖** គណៈប្រតិភូកម្ពុជាបានចូលរួម៖

ក សុន្ទរកថាគន្លឹះៗ( Keynote )ស្តីពី«ការគ្រប់គ្រងទឹក តាមរយៈសន្តិសុខទឹក និងភាពជាដៃគូ និងផលប៉ះពាល់នៃតំបន់ដីសណ្តក្នុងបណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍»

ខ .កិច្ចពិភាក្សាអំពី៖ ១ .សន្តិសុខទឹក និងភាពជាដៃគូ ២ .និយ័តករ និងភាពជាដៃគូ ៣ .ភាពជាដៃគូក្នុងការលើកកម្ពស់ការគ្រប់គ្រងទឹក ៤ .ការអនុវត្តឧបករណ៍សង្កេតសម្រាប់ការពង្រឹងការគ្រប់គ្រងទឹក ៥ .គោលនយោបាយគ្រប់គ្រងប្រព័ន្ធជាវាសាស្ត្រក្នុងប្រទេសថៃ។

## ❖ ការចូលរួមសន្និសីទទឹកវៀតណាម Vietnam Water Week 2023

តបតាមការអញ្ជើញរបស់សមាគមទឹកវៀតណាម ថ្ងៃទី២៨-៣០ ខែកញ្ញា ឆ្នាំ២០២៣ សមាគមCWA បានចូលកម្មវិធី Vietnam Water Week ២០២៣ និងពិធីសម្ពោធបណ្តាញការងារ នៅទីក្រុង BINH Duong, Vietnam ដែលបានបង្ហាញពីសារៈសំខាន់នៃកិច្ចសហការ និងការចែករំលែកពីចំណាប់អារម្មណ៍លើការគ្រប់គ្រងទឹកស្អាត និងទឹកកខ្វក់។ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ សមាគមCWA បានចូលរួមកិច្ចប្រជុំបណ្តាញការងារសមាគមទឹកអាស៊ីអាគ្នេយ៍ (SEAWUN)។ កម្មវិធីនេះមានរបៀបវារៈដូចជា៖ ១.ពង្រាងកម្មវិធី និងផែនការសកម្មភាពរបស់ SEAWUN ២.កិច្ចប្រជុំរវាង SEAWUN និងអង្គការ Water.org ស្តីពី «កម្មវិធី Water Equity» ៣.កិច្ចប្រជុំរវាង SEAWUN និង Global Water

Leader Group-Global Water Intelligence ស្ដីពី«គំនិតផ្ដួចផ្ដើមរបស់មេដឹកនាំលើការងារទឹកប្រហែល ៣០០ និងការផ្លាស់ប្តូរបទពិសោធន៍រវាងសមាជិក SEAWU និងសហគ្រាសទឹកធំជាងគេ ៣០០ នៅលើពិភពលោក» នៅក្រុង Binh Doung។




*រូបភាពទី១៩៖ គណៈប្រតិភូសមាគមបានចូលរួមក្នុងកិច្ចប្រជុំ Vietnam Water Week ២០២៣*



*រូបភាពទី២០៖ គណៈប្រតិភូសមាគមបានចូលរួមក្នុងកិច្ចប្រជុំបណ្ដាញការងារសមាគមទឹកអាស៊ីអាគ្នេយ៍ SEAWUN*

## ២.៥. កិច្ចប្រជុំថ្នាក់តំបន់

ក្នុងត្រីមាសទី៣ សមាគមបានរៀបចំកិច្ចប្រជុំថ្នាក់តំបន់ចំនួន ២លើក ក្នុងគោលបំណងដូចខាងក្រោម៖

១. បង្កើនទំនាក់ទំនងរវាងសមាជិក និងថ្នាក់ដឹកនាំសមាគម ក៏ដូចជារវាងសមាជិក និងសមាជិក

២. ស្វែងយល់ពីការរីកចម្រើន បញ្ហាប្រឈមរបស់សមាជិកកំពុងជួបប្រទះ ស្វែងរកដំណោះស្រាយរួមគ្នា និងបង្កើតផែនការសកម្មភាព

៣. ធ្វើបច្ចុប្បន្នភាពអំពីច្បាប់ស្ដីពីការគ្រប់គ្រងទឹកស្អាត និង

៤. ចែករំលែកចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាថ្មីៗ។

❖ **លើកទី១៖** ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ បានរៀបចំនៅសណ្ឋាគារ និងភោជនីយដ្ឋានភ្នំប្រុស ខេត្តកំពង់ចាម ដែលមានការឧបត្ថម្ភពីក្រុមហ៊ុន LESSO Cambodia។ កិច្ចប្រជុំនេះមានអ្នកចូលរួមសរុបចំនួន ៥៣នាក់ (ស្រី ១២នាក់) រួមមាន៖ តំណាងមន្ទីរ ឧរបន ខេត្តកំពង់ចាម ក្រុមប្រឹក្សាភិបាលសមាគម បុគ្គលិកសមាគម បុគ្គលិកក្រុមហ៊ុន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន៣៨ស្ថានីយ មកពីខេត្តកំពង់ចាម កំពង់ធំ ត្បូងឃ្មុំ ក្រចេះ និងព្រៃវែង។



*រូបភាពទី៨៖ កិច្ចប្រជុំថ្នាក់តំបន់នៅខេត្តកំពង់ចាម*

❖ **លើកទី២៖** ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣ នៅសណ្ឋាគារផាមរីវើ ខេត្តកំពង់ស្ពឺ ដែលបានទទួលការឧបត្ថម្ភពីក្រុមហ៊ុនបីរួមមាន៖ ១. ក្រុមហ៊ុន ធីស៊ីយូប៉ូលី អេធើប្រាយ ២. ក្រុមហ៊ុន ភ្នំពេញ ប្លាស្ទិច ប្រូដាក់ និង ៣. ក្រុមហ៊ុន វ៉ធើរ ផាតនើរ (ខេមបូឌា) ឯ.ក។ កិច្ចប្រជុំនេះមានអ្នកចូលរួមសរុបចំនួន ៥៤នាក់ (ស្រី០៩នាក់) រួមមាន៖ ប្រធានមន្ទីរ ឧរបន ខេត្តកំពង់ស្ពឺ និងសហការី ក្រុមប្រឹក្សាភិបាលសមាគម បុគ្គលិកសមាគម បុគ្គលិកក្រុមហ៊ុន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន ៣២ស្ថានីយ ដែលជាប្រតិបត្តិករអ្នកផ្គត់ផ្គង់ទឹកស្អាតមកពីខេត្តកំពង់ស្ពឺ តាកែវ កំពត និងព្រះសីហនុ។



*រូបភាពទី៩៖ កិច្ចប្រជុំថ្នាក់តំបន់នៅខេត្តកំពង់ស្ពឺ*

## ២.៦. វគ្គបណ្តុះបណ្តាល

ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ សមាគមបានសហការជាមួយសាខាពន្ធដារ និងមន្ទីរ ឧវបន ខេត្តកណ្តាល បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី«សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និងនីតិវិធីនៃការបង់ពន្ធរបស់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត» នៅសណ្ឋាគារសាន់វេ ភ្នំពេញ ដែលមានអ្នកចូលរួមសរុបចំនួន ៣៧នាក់ (ស្ត្រី១១នាក់)។



*រូបភាពទី១០៖ រូបថតអនុស្សាវរីយ៍ជាមួយគណអធិបតី*

វគ្គបណ្តុះបណ្តាលនេះផ្តោតទៅលើប្រធានបទដូចខាងក្រោម៖

- ការចុះបញ្ជីពន្ធដារនិងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ
- កាតព្វកិច្ចនៃការបង់ពន្ធសម្រាប់អាជីវករផ្គត់ផ្គង់ទឹកស្អាត
- សិទ្ធិ និង កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ
- សិទ្ធិ និង កាតព្វកិច្ចរបស់ភ្នាក់ងារសេវាកម្មពន្ធដារ
- ការចែករំលែកបទពិសោធន៍ទៅលើការប្រកាសពន្ធ



*រូបភាពទី១១៖ ការចូលរួមរបស់សិក្ខាកាមក្នុងវគ្គបណ្តុះបណ្តាល*

## ៣.    ការងារគម្រោង

### ៣.១. គម្រោង«ការកែលម្អលទ្ធភាពទទួលបានហិរញ្ញប្បទានរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននៅកម្ពុជា ដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាត» ( Water.org )

#### ៣.១.១. ការពង្រឹងសមត្ថភាពប្រតិបត្តិករលើប្រព័ន្ធគណនេយ្យ

នៅក្នុងត្រីមាសទី៣ ក្រុមការងាររបស់គម្រោងបានសហការជាមួយក្រុមហ៊ុន អ៊ី-ផៅវ័ រ សុី សុី អិល ឯ.ក រៀបចំវគ្គបណ្តុះបណ្តាលចំនួន ២វគ្គ ដូចខាងក្រោម៖

- លើកទី១៖ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣ នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ ស្តីពី«មូលដ្ឋានគ្រឹះគណនេយ្យសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត»។ សមាសភាពអ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះសរុបមានចំនួន ៤២នាក់(ស្ត្រី ១៨នាក់) ដែលអញ្ជើញមកពីអគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួង ឧវបន ចំនួន ២នាក់ តំណាងអង្គការ Water.org កម្ពុជា ចំនួន ១នាក់ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន ៣២ នាក់ បុគ្គលិកក្រុមហ៊ុន អ៊ី-ផៅវ័រ សុី សុី អិល ឯ.ក ចំនួន ៣នាក់ និងបុគ្គលិកសមាគមចំនួន ៤នាក់។



*រូបភាពទី១១៖ ការធ្វើបទបង្ហាញដោយអ្នកជំនាញមកពីក្រុមហ៊ុន អ៊ី-ផៅវ័រ*

- លើកទី២៖ ថ្ងៃទី២៤-២៥ ខែសីហា ឆ្នាំ២០២៣ នៅសណ្ឋាគារ សាន់វ៉េ រាជធានី ស្តីពី «ប្រព័ន្ធគណនេយ្យពេញលេញ E-Water Software» ដែលមានអ្នកចូលរួមសរុបចំនួន ៤៨នាក់ (ស្រី ២៣នាក់)។ អ្នកចូលរួមអញ្ជើញមកពីអគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួង ឧវបន ចំនួន ២នាក់ គ្រូជំនាញពីក្រុមហ៊ុន E-Power CCL ចំនួន៤នាក់ ស្រី១នាក់ បុគ្គលិកសមាគមចំនួន ៣នាក់ និងប្រតិបត្តិករចំនួន ៣៩នាក់ ។



*រូបភាពទី១២៖ ការធ្វើបទបង្ហាញស្តីពីប្រព័ន្ធគណនេយ្យពេញលេញ ដោយលោក ខឹម សំណាង*

## ៣.១.២. ការឧបត្ថម្ភធនលើឧបករណ៍តេស្តគុណភាពទឹកស្អាត

ក្នុងត្រីមាសទី៣ គម្រោងបានសម្របសម្រួលក្នុងការទិញឧបករណ៍តេស្តគុណភាពទឹកទាំង ៥ប៉ារ៉ាម៉ែត្រ និងឧបករណ៍វាស់សម្ពាធទឹកចុងបណ្តាញ ជូនប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន។ ជាលទ្ធផលប្រតិបត្តិករចំនួន ២២ ស្ថានីយបានស្នើសុំឧបករណ៍ធ្វើតេស្តគុណភាពទឹក ក្រោមមូលនិធិឧបត្ថម្ភធនរបស់គម្រោង។ ថវិកាសរុបសម្រាប់ទិញឧបករណ៍តេស្តគុណភាពទឹកមានចំនួន ២០.៧៧៣,៥០ដុល្លារអាមេរិក ដែលឧបត្ថម្ភធនដោយគម្រោងចំនួនទឹកប្រាក់ ៨.៥៩៦,៥០ដុល្លារអាមេរិក និងចូលរួមបដិភាគពីប្រតិបត្តិករមានចំនួនទឹកប្រាក់ ១២.១៧៧,០០ដុល្លារអាមេរិក។

## ៣.១.៣. ការសម្របសម្រួលកម្ចីរវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងស្ថាប័នហិរញ្ញវត្ថុ

ក្នុងត្រីមាសទី៣ ក្រុមការងារគម្រោងបានជួបប្រជុំជាមួយស្ថាប័នពាក់ព័ន្ធ ដូចខាងក្រោម៖

១. អង្គការ Water.org សមាគម CWA ធនាគារ SME និងម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំនួនពីរស្ថានីយបានជួបប្រជុំដើម្បីពិភាក្សាអំពីដំណើរការកម្ចី និងរបៀបគាំទ្រដល់ប្រតិបត្តិករក្នុងការទទួលបានហិរញ្ញប្បទាន ជាពិសេសពិភាក្សាលើការវាយតម្លៃទ្រព្យបញ្ចាំឱ្យបានសមស្របទៅនឹងតម្លៃទីផ្សារ។ ជាលទ្ធផល ធនាគារ SME បានពិចារណាឡើងវិញនូវការវាយតម្លៃលើទ្រព្យបញ្ចាំប្រតិបត្តិករឡើងវិញ និងស្នើឱ្យប្រតិបត្តិករពិចារណាជួលក្រុមហ៊ុនវាយតម្លៃអចលនៈទ្រព្យឯករាជ្យវាយតម្លៃលើទ្រព្យរបស់ពួកគេផ្ទាល់។

២. តំណាងសមាគម និងក្រុមហ៊ុនក្រេឌីតប្យូរ៉ូ (ខេមបូឌា) ខូអិលធីឌី (ស៊ីប៊ីស៊ី) មានកិច្ចប្រជុំមួយដើម្បីណែនាំអំពីសមាគម វិស័យផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ និងអំពីក្រុមហ៊ុន CBC និងពិភាក្សាអំពីភាពជាដៃគូនាពេលអនាគត។

ក្រុមការងារគម្រោងក៏បានសម្របសម្រួលការផ្តល់ប្រាក់កម្ចីដល់ប្រតិបត្តិករចំនួន ៥ស្ថានីយ។ ជាលទ្ធផលប្រតិបត្តិករទឹកស្អាតចំនួន ២ស្ថានីយ ទទួលបានការអនុម័តកម្ចីពីធនាគារ SME ដែលមានទំហំទឹកប្រាក់ចំនួន ១.២៥០.០០០ ដុល្លារអាមេរិក។ លើសពីទៅនេះទៀត សមាគមក៏បានសម្របសម្រួលឱ្យមានការបញ្ចុះការប្រាក់ ដោយយោងលើអនុស្សរណៈយោគយល់គ្នា រវាងសមាគម CWA និងធនគារ SME ដូច្នេះខាងធនាគារ SME បានបញ្ចុះតម្លៃលើអត្រាការប្រាក់បន្ថែមចំនួន ០,២៥% ក្នុងមួយឆ្នាំជូនដល់ប្រតិបត្តិករទាំង ២ថែមទៀត។

### ៣.១.៤. កិច្ចសហការជាមួយអគ្គនាយកដ្ឋានទឹកស្អាត

ក្រុមការងារគម្រោងបានសម្របសម្រួលកិច្ចប្រជុំជាមួយអគ្គនាយកដ្ឋានទឹកស្អាតបានចំនួន ២លើក៖

- ❖ កិច្ចប្រជុំលើកទី១៖ កិច្ចប្រជុំពិភាក្សាអំពីផែនការកសាងសមត្ថភាពផ្នែកបច្ចេកទេសដល់ប្រតិបត្តិករនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣។
- ❖ កិច្ចប្រជុំលើកទី២៖ កិច្ចប្រជុំពិភាក្សាលើរបៀបវារៈនៃវគ្គបណ្តុះបណ្តាលបច្ចេកទេស និងកាលវិភាគនៃវគ្គបណ្តុះបណ្តាល នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣។

### ៣.១.៥. ការផលិតវីដេអូ

ក្រុមការងារគម្រោងបានសម្របសម្រួលផលិតវីដេអូអប់រំអំពីសេវាទឹកស្អាតដូចខាងក្រោម៖

១. វីដេអូអប់រំខ្លីស្តីពី«**សារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាតតាមបំពង់**» ដែលបានសហការ និងផលិតនៅទីតាំងស្ថានីយទឹកស្អាតកំពង់ចំលង និងស្ថានីយទឹកស្អាតស្វាយរមៀត។

តំណភ្ជាប់៖ https://www.youtube.com/watch?v=TNMt44dX3VQ&t=55s




*រូបភាពទី១៣៖ រូបភាពដកស្រង់ចេញពីវីដេអូស្តីពីសារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាត*

២. គម្រោងបានផ្សព្វផ្សាយអំពីការប្រកួតប្រជែងផលិតវីដេអូអប់រំខ្លីអំពីសេវាផ្គត់ផ្គង់ទឹកស្អាតផងដែរ។ ជាលទ្ធផល មានវីដេអូចំនួនពីរដែលបានផ្ញើមកសមាគម ហើយគណកម្មការពិនិត្យលើវីដេអូទាំងពីរនោះឃើញថា មិនអាចទទួលយកបាន។ គម្រោងសម្រេចថា មិនបន្តការផ្សព្វផ្សាយអំពីការប្រកួតប្រជែងផលិតវីដេអូអប់រំខ្លីទៀតទេ។

## ៣.២. គម្រោង«សមត្ថភាពដើម្បីការអនុវត្តប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម ( CO-SAVED)

### ៣.២.១. វគ្គបណ្តុះបណ្តាល

នៅក្នុងត្រីមាសទី៣ នេះក្រុមការងារគម្រោងបានរៀបចំវគ្គបណ្តុះបណ្តាលដូចខាងក្រោម៖

១. នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារគម្រោងបានរៀបចំវគ្គបណ្តុះបណ្តាលនៅសាលប្រជុំរបស់សាលាស្រុកកំពង់សីលា ខេត្តព្រះសីហនុ ដើម្បីពង្រឹងសមត្ថភាពអាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ឱ្យយល់ដឹងអំពីតួនាទី និងការទទួលខុសត្រូវលើសេវាកម្មផ្គត់ផ្គង់ទឹកស្អាត ព្រមទាំងបច្ចេកទេសក្នុងផលិតទឹកស្អាត ថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងការតាមដានគុណភាពទឹកស្អាតប្រចាំថ្ងៃ។

២. វគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពីការដឹកនាំការផ្សព្វផ្សាយសហគមន៍ឱ្យយល់អំពី«សារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាតតាមបំពង់ វិធីសាស្ត្រក្នុងការបន្សុតទឹក និងការទុកដាក់ទឹកឱ្យមានសុវត្ថិភាព» ត្រូវបានរៀបចំតាមកាលបរិច្ឆេទ និងទីតាំងដូចខាងក្រោម៖

   ក. ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣ នៅសាលប្រជុំសាលាស្រុកកំពង់ត្រាច
   ខ. ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣ នៅសាលប្រជុំសាលាស្រុកទឹកឈូ ខេត្តកំពត
   គ. ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣ នៅសាលប្រជុំសាលាស្រុកដំណាក់ចង្អើរ
   ឃ. ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ នៅសាលប្រជុំសាលាស្រុកស្ទឹងហាវ
   ង. ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣ នៅសាលប្រជុំសាលាស្រុកព្រៃនប់
   ច. ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣ នៅសាលប្រជុំសាលាស្រុកកំពង់សីលា។



*រូបភាពទី១៤៖ វគ្គបណ្តុះបណ្តាលថ្នាក់ស្រុក*

## ៣.៣. គម្រោង«សហគមន៍ដឹកនាំទឹកស្អាត និងអនាម័យធន់នឹងអាកាសធាតុប្រកបដោយបរិយាប័ន្ន» (EMW)

### ៣.៣.១. វគ្គបណ្ដុះបណ្ដាល

ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ គម្រោងបានរៀបចំវគ្គបណ្ដុះបណ្ដាលរំលឹកឡើងវិញជូនដល់ប្រតិបត្តិករដែលជាស្ត្រីអ្នកដឹកនាំក្នុងអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។ វគ្គនេះមានអ្នកចូលរួមសរុបចំនួន ២១នាក់ (ស្រី ៥នាក់) ដែលជាបុគ្គលិក និងម្ចាស់ស្ថានីយចំនួន ១០នាក់ ដែលមកពី ៥ស្ថានីយ មន្ត្រីអង្គការ EMW ៥នាក់ មន្ត្រីអង្គការ DPO ១នាក់ មន្ត្រីអង្គការ CDRI ១នាក់ និងបុគ្គលិកសមាគម ៤នាក់។ វគ្គបណ្ដុះបណ្ដាលផ្ដោតលើប្រធានបទ៖ ១.តួនាទី និងការទទួលខុសត្រូវរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និង ច្បាប់ស្ដីពីការគ្រប់គ្រងទឹកស្អាត ២. ស្តង់ដារគុណភាពទឹកស្អាត ៣.យុទ្ធសាស្ត្រទីផ្សារសម្រាប់បង្កើនតំណ និងការងារសង្គម ៤.មូលដ្ឋានគ្រឹះនៃគណនេយ្យ និងការកត់ត្រាចំណូលចំណាយ។



*រូបភាពទី១៥៖ ការថតរូបអនុស្សាវរីយ៍ក្រោយបញ្ចប់វគ្គបណ្ដុះបណ្ដាល*

### ៣.៣.២. សិក្ខាសាលា

ថ្ងៃទី១២-១៥ ខែកញ្ញា ឆ្នាំ២០២៣ ក្រោមការឧបត្ថម្ភពីអង្គការ EMW បុគ្គលិកសមាគមចំនួន ២នាក់បានចូលរួមក្នុងសិក្ខាសាលាស្តីពីឧបករណ៍វាយតម្លៃដោយខ្លួនឯងលើសមភាពយេនឌ័រ ពិការភាព និងបរិយាប័ន្ន នៅរាជធានីភ្នំពេញ។ សមាសភាពអ្នកចូលរួមអញ្ជើញមកពីប្រទេស កម្ពុជា ឡាវ និងវៀតណាម ចំណែកឯអ្នកសម្របសម្រួលអញ្ជើញមកពីប្រទេសអូស្ត្រាលី និងឥណ្ឌា។



*រូបភាពទី១៦៖ ការថតរូបអនុស្សាវរីយ៍ក្នុងសិក្ខាសាលា*

## ៣.៤. គម្រោង «ការពង្រឹងប្រព័ន្ធផែនការគ្រប់គ្រងធនធានទឹក សម្រាប់សេវាកម្មទឹកស្អាត និងអនាម័យធន់នឹងអាកាសធាតុ ប្រកបដោយបរិយាប័ន្ននៅក្នុងប្រទេសកម្ពុជា»

### ៣.៤.១. វគ្គបណ្តុះបណ្តាល

តាមរយៈការឧបត្ថម្ភពីសកលវិទ្យាល័យបច្ចេកវិទ្យាទីក្រុងស៊ីដនី University of Technology Sydney (UTS) សមាគមបានរៀបចំវគ្គបណ្តុះបណ្តាលចំនួនពីរដូចខាងក្រោម៖

១. វគ្គបណ្តុះបណ្តាលស្តីពី«ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុសម្រាប់ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត» នៅថ្ងៃទី២៤-២៥ ខែសីហា ឆ្នាំ២០២៣។ វគ្គនេះមានគោលបំណង ដើម្បីឱ្យប្រតិបត្តិករត្រៀមខ្លួនរៀបចំឱ្យប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតមានភាពបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ សម្រាប់ការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាជនប្រកបដោយគុណភាព សុវត្ថិភាព និងនិរន្តភាព។ សមាសភាពអ្នកចូលរួមមាន៖ មន្ត្រីរដ្ឋបាលស្រុក ឃុំ ភូមិ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ដែលកំពុងផ្គត់ផ្គង់ទឹកស្អាត តំណាងអង្គការជនពិការនៅក្នុងស្រុកសាមគ្គីមានជ័យ។



*រូបភាពទី១៧៖ វគ្គបណ្តុះបណ្តាល ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ សម្រាប់សេវាផ្គត់ផ្គង់ទឹកស្អាត*

២. វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញស្តីពី«វិធានការកាត់បន្ថយផលប៉ះពាល់អំពីគ្រោះទឹកជំនន់ និងកាត់បន្ថយផលប៉ះពាល់អំពីគ្រោះរាំងស្ងួតសម្រាប់ការផ្តល់សេវាកម្មទឹកស្អាត» ដែលបានរៀបចំឡើងនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ នៅសាលប្រជុំសាលាស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។ វគ្គនេះមានគោលបំណង ដើម្បីឆ្លុះបញ្ចាំងពីការរៀបចំធ្វើផែនការសុវត្ថិភាពទឹកដែលធន់នឹងអាកាសធាតុសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ ជាពិសេសការកាត់បន្ថយហានិ-ភ័យនិងផលប៉ះពាល់ពីគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតព្រមទាំងការរៀបចំរបាយការណ៍ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុផងដែរ។ សមាសភាពអ្នកចូលរួមមាន៖ មន្ត្រីរដ្ឋបាលស្រុក ឃុំ ភូមិ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន តំណាងអង្គការជនពិការនៅក្នុងស្រុកសាមគ្គីមានជ័យ តំណាងអង្គការ WaterAid និងតំណាងអង្គការ CDRI។



*រូបភាពទី១៨៖ វគ្គបណ្តុះបណ្តាល រំលឹកឡើងវិញ នៅស្រុកសាមគ្គីមានជ័យ*